**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**១២៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៣២៥,០០៨០ ហិកតា នៅស្រុកឈូក ខេត្តកំពត ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនយោធិនសមាហរណកម្មព្រមទាំងគ្រួសារ នៃកងពលតូច លេខ ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹកចំនួន ៦៧ គ្រួសារ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៣៦/១៧ ល.ស ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- លិខិតលេខ ១០៦០ ដនស/អសក ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ ៤៦៦៣ កសក ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ ៣២៥,០០៨០ ហិកតា ចេញពីដីតម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនយោធិនសមាហរណកម្មព្រមទាំងគ្រួសារ នៃកងពលតូច លេខ ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹកចំនួន ៦៧ គ្រួសារ ទំហំ ៣១៣,១៦៨៩ ហិកតា និងផ្ទៃដីទំហំ ១១,៨៣៩១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃ៣យ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត តាមប្រព័ន្ធកូអរដោនេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ដើម្បីធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនយោធិនសមាហរណកម្មព្រមទាំងគ្រួសារ នៃកងពលតូចលេខ ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹក នៅភូមិព្រៃ៣យ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ។



www.pheakdeylaw.com

**មាត្រា ៣** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពតត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ...១២៦ អនក្រ.បក...............ចុះថ្ងៃទី...០៣....ខែ...សីហា.....ឆ្នាំ ២០១៧ ស្តីពីការកាត់ដីទំហំ ៣២៥,០០៨០ ហិកតា នៅភូមិព្រៃពាយ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦៧ គ្រួសារ កាន់កាប់ជាំផុះជាក់ស្តែង និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ




| ចំណុច | Y | X | ចំណុច | Y | X |
|---|---|---|---|---|---|
| 1 | 1200323 | 405531 | 36 | 1202334 | 405276 |
| 2 | 1200323 | 405148 | 37 | 1202226 | 405216 |
| 3 | 1200323 | 404531 | 38 | 1202056 | 405121 |
| 4 | 1204240 | 403983 | 39 | 1201986 | 405107 |
| 5 | 1204240 | 405150 | 40 | 1201814 | 405181 |
| 6 | 1204129 | 405169 | 41 | 1201772 | 405226 |
| 7 | 1203465 | 405284 | 42 | 1201760 | 405276 |
| 8 | 1203458 | 405226 | 43 | 1201782 | 405398 |
| 9 | 1203604 | 405158 | 44 | 1201797 | 405479 |
| 10 | 1203701 | 405072 | 45 | 1201331 | 405496 |
| 11 | 1203813 | 405024 | 46 | 1200369 | 405172 |
| 12 | 1203913 | 404798 | 47 | 1200398 | 405305 |
| 13 | 1203528 | 405041 | 48 | 1200444 | 405345 |
| 14 | 1203423 | 405020 | 49 | 1200648 | 405331 |
| 15 | 1203275 | 405011 | 50 | 1200735 | 405329 |
| 16 | 1203150 | 404931 | 51 | 1200867 | 405256 |
| 17 | 1203127 | 404782 | 52 | 1201018 | 405236 |
| 18 | 1203037 | 404840 | 53 | 1201121 | 405239 |
| 19 | 1202583 | 404960 | 54 | 1201248 | 405168 |
| 20 | 1202416 | 405057 | 55 | 1201306 | 405159 |
| 21 | 1202416 | 405420 | 56 | 1201307 | 405070 |
| 22 | 1202461 | 405433 | 57 | 1201382 | 404990 |
| 23 | 1202561 | 405320 | 58 | 1201554 | 404876 |
| 24 | 1202756 | 405406 | 59 | 1201604 | 404823 |
| 25 | 1202598 | 405434 | 60 | 1201356 | 404664 |
| 26 | 1202601 | 405408 | 61 | 1201166 | 404628 |
| 27 | 1202563 | 405406 | 62 | 1201057 | 404621 |
| 28 | 1202556 | 405437 | 63 | 1201014 | 404641 |
| 29 | 1202473 | 405456 | 64 | 1200955 | 404764 |
| 30 | 1202381 | 405459 | 65 | 1200841 | 404782 |
| 31 | 1202046 | 405471 | 66 | 1200765 | 404731 |
| 32 | 1202061 | 405454 | 67 | 1200656 | 404761 |
| 33 | 1202139 | 405447 | 68 | 1200623 | 404709 |
| 34 | 1202196 | 405344 | 69 | 1200554 | 404645 |
| 35 | 1202293 | 405337 | 70 | 1200323 | 404766 |




## សញ្ញាសម្គាល់

- ● ភូមិ
- ■ ឃុំ
- ⬟ ដីភ្នំ
- ព្រំប្រទល់ដីកាត់ចេញចំនួនសរុប ៣២៥,០០៨០ ហិកតា
- ▲ ចំនុចគោល
- ● ការធ្វើប្រទានកម្មដីជូនប្រជាពលរដ្ឋចំនួន ៣១៣,១៦៤៩ ហិកតា
- ● រក្សាទុកដីសាធារណៈរបស់រដ្ឋចំនួន ១១,៨៣៨១ ហិកតា
- ស្ទឹង
- ផ្លូវ

### ទិន្នន័យគម្របព្រៃឈើ២០០២

- ព្រៃស្រោង
- ព្រៃពាក់កណ្តាលស្រោង
- ព្រៃល្បោះ
- ដីគ្មានគម្របព្រៃ

Coordinate System Projection UTM Zone 48N Map Datum:WGS84

N

មាត្រដ្ឋាន 1:20,000

0 262.5 525 1,050 1,575 2,100 Meters

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ...១២៦...អនក្រ.បក...............ចុះថ្ងៃទី...០៨....ខែ...សីហា.....ឆ្នាំ ២០១៧ស្តីពីការកាត់ដីទំហំ ៣២៥,០០៨០ ហិកតា នៅភូមិព្រៃពាយ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ចេញពីតំបន់ព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦៧ គ្រួសារ កាន់កាប់ដាំដុះជាក់ស្តែង និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ



| ចំណុច | Y | X | ចំណុច | Y | X |
|---|---|---|---|---|---|
| 1 | 1200323 | 405531 | 36 | 1202334 | 405276 |
| 2 | 1200323 | 405148 | 37 | 1202225 | 405216 |
| 3 | 1200323 | 404531 | 38 | 1202056 | 405121 |
| 4 | 1204240 | 403983 | 39 | 1201996 | 405107 |
| 5 | 1204240 | 405150 | 40 | 1201814 | 405181 |
| 6 | 1204129 | 405169 | 41 | 1201772 | 405226 |
| 7 | 1203465 | 405284 | 42 | 1201760 | 405276 |
| 8 | 1203458 | 405226 | 43 | 1201782 | 405398 |
| 9 | 1203604 | 405158 | 44 | 1201797 | 405479 |
| 10 | 1203701 | 405072 | 45 | 1201331 | 405496 |
| 11 | 1203813 | 405024 | 46 | 1200369 | 405172 |
| 12 | 1203913 | 404798 | 47 | 1200398 | 405305 |
| 13 | 1203528 | 405041 | 48 | 1200444 | 405345 |
| 14 | 1203423 | 405020 | 49 | 1200648 | 405331 |
| 15 | 1203275 | 405011 | 50 | 1200735 | 405329 |
| 16 | 1203150 | 404931 | 51 | 1200867 | 405256 |
| 17 | 1203127 | 404782 | 52 | 1201018 | 405236 |
| 18 | 1203037 | 404840 | 53 | 1201121 | 405239 |
| 19 | 1202583 | 404960 | 54 | 1201248 | 405168 |
| 20 | 1202416 | 405057 | 55 | 1201306 | 405159 |
| 21 | 1202416 | 405420 | 56 | 1201307 | 405070 |
| 22 | 1202461 | 405433 | 57 | 1201382 | 404990 |
| 23 | 1202561 | 405320 | 58 | 1201554 | 404876 |
| 24 | 1202756 | 405406 | 59 | 1201504 | 404823 |
| 25 | 1202598 | 405434 | 60 | 1201358 | 404684 |
| 26 | 1202601 | 405408 | 61 | 1201166 | 404628 |
| 27 | 1202563 | 405406 | 62 | 1201057 | 404621 |
| 28 | 1202556 | 405437 | 63 | 1201014 | 404641 |
| 29 | 1202473 | 405456 | 64 | 1200955 | 404764 |
| 30 | 1202381 | 405459 | 65 | 1200841 | 404782 |
| 31 | 1202046 | 405471 | 66 | 1200765 | 404731 |
| 32 | 1202061 | 405454 | 67 | 1200656 | 404761 |
| 33 | 1202139 | 405447 | 68 | 1200623 | 404709 |
| 34 | 1202196 | 405344 | 69 | 1200554 | 404645 |
| 35 | 1202293 | 405337 | 70 | 1200323 | 404766 |

មាត្រដ្ឋាន 1:…000

វាស់វែង ដោយប្រើឧបករណ៍ GPS MAP 62s

កំពត ថ្ងៃទី...២៤.....ខែ...សីហា.....ឆ្នាំ២០១៧

អ្នកវាស់វែង

លេខ.២៤៣.... ជិន្ន ចាន់

បានឃើញ និងពិនិត្យត្រឹមត្រូវ

កំពត ថ្ងៃទី.......ខែ...សីហា....ឆ្នាំ២០១៧

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត

លេខ ២៣១៦/១៧ មុន-ខុដ

បានឃើញ និងឯកភាព

កំពត ថ្ងៃទី...១៥....ខែ...សីហា.....ឆ្នាំ២០១៧

អភិបាលខេត្ត និងជា

ប្រធានគណៈកម្មការរៀបចំគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត

ចាន់ ចេស្តា